# II. ទីស្ដីការគណៈរដ្ឋមន្ត្រី

# ១. អនុក្រឹត្យ

*ភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣*

## អនុក្រឹត្យ លេខ ០៩ អនក្រ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ នរោត្តម សីហនុវរ្ម័នព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់ឯកឧត្ដម ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១ :** ប្រាក់បំណាច់និងរបបឧបត្ថម្ភជីវភាព ចំណាយសំរាប់ផ្ដល់មុខសញ្ញាមួយចំនួនត្រូវបានកំណត់ដូចខាងក្រោម ÷

- ផ្ដល់ប្រាក់បំណាច់បំពេញបេសកកម្មក្នុងប្រទេសជូនដល់មន្ត្រីរាជការមួយនាក់ ក្នុងមួយថ្ងៃចំនួនប្រាំពាន់ ( ៥.000 ) រៀល ។

- ផ្ដល់ប្រាក់ឧបត្ថម្ភសំរាប់ចំណាយបំរើអោយដល់អ្នកជំងឺដែលសំរាកព្យាបាលរោគក្នុងមន្ទីរពេទ្យ រដ្ឋនានាទូទាំងព្រះរាជាណាចក្រកម្ពុជា មួយនាក់ ក្នុងមួយថ្ងៃ មួយពាន់ ( ១.000 ) រៀល ។

- ផ្ដល់របបជីវភាពសំរាប់ទណ្ឌិត និងពិរុទ្ធជនដែលជាប់ឃុំក្នុងពន្ធនាគារ ឬមន្ទីរឃុំឃាំងទូទាំងព្រះរាជាណាចក្រកម្ពុជា មួយនាក់ក្នុងមួយថ្ងៃចំនួន មួយពាន់ ( ១.000 ) រៀល ។

**មាត្រា ២ :** រាល់ការកំណត់ទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលមានការពាក់ព័ន្ធ និងអភិបាលគ្រប់ ខេត្ត- ក្រុង ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រហស្តលេខានិងចុះហត្ថលេខាតទៅ។

ជ.រាជរដ្ឋាភិបាលកម្ពុជា

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា | ហត្ថលេខា |
| ស្តេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

******